**កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម**




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights andInternational Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៤០

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មភាគច្រើនធ្វើឡើងជាអសាធារណៈ។ វគ្គសវនាការ “ជាអសាធារណៈ” ត្រូវបានធ្វើឡើងក្នុងរយៈពេលពីរថ្ងៃពេញនៅថ្ងៃចន្ទ និងថ្ងៃអង្គារ ចំពោះសាក្សីដែលកំពុងស្ថិតក្នុងការស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤ ។ ទោះបីជាហេតុផលនៃការបើកសវនាការជាអសាធារណៈពុំត្រូវបានប្រកាសដោយអង្គជំនុំជម្រះជាមុនក៏ដោយ ក៏វគ្គសវនាការពេលព្រឹកនៅថ្ងៃបន្ទាប់ ត្រូវបានរៀបចំឡើងជាអសាធារណៈផងដែរ ដើម្បីស្តាប់សក្ខីកម្មរបស់សាក្សីដែលមានអត្តលេខ 2-TCW-938 ។ សេចក្តីសង្ខេបស្តីពីសក្ខីកម្មរបស់សាក្សីទាំងបីរូបខាងលើនេះ នឹងត្រូវចុះផ្សាយក្នុងរបាយការណ៍នៅពេលខាងមុខ នៅណាពេលដែលប្រតិចារឹកកោសលប់ ស្តីពីកិច្ចដំណើរការនីតិវិធីជាអសាធារណៈទាំងនេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដែលអ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមអាចប្រើប្រាស់បាន។ នៅពេលដែលសវនាការត្រូវបានធ្វើឡើងជាសាធារណៈជាថ្មីឡើងវិញនៅពេលរសៀលថ្ងៃពុធ អង្គជំនុំជម្រះបានប្រកាសថាមានតែបុគ្គលមួយរូបប៉ុណ្ណោះដែលនឹងមកបង្ហាញខ្លួនជាសាធារណៈក្នុងសប្តាហ៍នេះ គឺលោកដើមបណ្តឹងរដ្ឋប្បវេណី **ឡាច គ្រី** ដែលបានផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ដោយសារតែបញ្ហាសុខភាពទ្រុឌទ្រោមរបស់គាត់។[1] លោក **ឡាច គ្រី** បានផ្តល់សក្ខីកម្មស្តីពីសេចក្តីរងទុក្ខវេទនាដែលគាត់ និងបងប្អូនប្រុសរបស់គាត់ គឺលោក **ឡាច នី** បានឆ្លង

[1] អង្គជំនុំជម្រះសាលាដំបូង “សេចក្តីសម្រេចទៅលើការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCW-844” ( ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ ) លេខ E385 ។

កាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានធ្វើការរៀបរាប់យ៉ាងលម្អិតអំពីការចាប់ខ្លួនប្រពន្ធ និងកូនៗបងប្អូនរបស់គាត់ដែលជាជនជាតិភាគតិចវៀតណាម នៅក្នុងភូមិពោធិ៍ចិនដាំ ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ហើយក៏បានរៀបរាប់ផងដែរអំពីការបាត់ខ្លួនរបស់ក្រុមគ្រួសារខ្មែរកាត់វៀតណាមចំនួនពីរគ្រួសារផ្សេងទៀត ដែលបានរស់នៅទីនោះ។[2] ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានបិទបញ្ចប់នៅវគ្គសវនាការពេលរសៀលថ្ងៃព្រហស្បតិ៍ ជាមួយនឹងការថ្លែងពីការពន្យសនកម្មរបស់គាត់ផងដែរ។ អង្គជំនុំជម្រះសាលាដំបូង នឹងបើកសាវនាការសាជាថ្មីនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ជាសាធារណៈ ជាមួយនឹងការស្តាប់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម 2-TCCP-869 ។

---

*របាយការណ៍នេះ ត្រូវបានសរសេរដោយ អាឡិចសាន់ឌើ បេនហ្ស (Alexander Benz), ជា បូរ៉ាក់មុន្នី, ខេតលីន កាហ្វ្រៀ (Caitlin McCaffrie), អេលីហ្សាប៊ែត អ័រ(Elizabeth Orr), ធី ស៊ុន (Thi Son), តាយ លីណា និងភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។AIJIគឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu)និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (THE WSD HANDA Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជាមជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាមប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

---

[2] សម្រាប់សេចក្តីសង្ខេបអំពីសក្ខីកម្មរបស់លោក ថេង ផល សូមមើលរបាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម ក្នុងសំណុំរឿង០០២ វគ្គ២ លេខ៣៨ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៣៥ (ចុះថ្ងៃទី៥ ដល់ទី៨ ខែមករា ឆ្នាំ២០១៦) ទំព័រ ៣ ដល់ ៤។